**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តតាកែវ**
លេខៈ ...១៣១.... ស.ស.រ

តាកែវ, ថ្ងៃទី ១១ខែ ធ្នូ ឆ្នាំ២០១៥

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១

## អភិបាលខេត្តតាកែវ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/២៩៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ២០១៤ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថនរោត្តមសីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តតាកែវ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ ផលិតផល១ ដោយធ្វើសមាហរណកម្មការងារជំរុញចលនាភូមិ១ ផលិតផល១ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មជនបទ។
- យោងសេចក្តីសម្រេចលេខ ១១៧ សសរ/១៤ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ របស់រដ្ឋបាលខេត្តតាកែវ ស្តីពីការបែងចែក និងប្រគល់តួនាទីភារកិច្ចជូនឯកឧត្តមអភិបាល អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ។
- យោងលិខិតលេខ ០៣២ ភ១ ផ១ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទស្តីពីការណែនាំឲ្យរដ្ឋបាលរាជធានី ខេត្តរៀបចំគណៈកម្មាធិការជំរុញចលនាភូមិ១ ផលិតផល១។
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តតាកែវ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ សរសេរអក្សរកាត់ថា(គ.ខ.ភ១.ផ១) ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ឡាយ វណ្ណៈ** | អភិបាលខេត្ត | ប្រធាន |
| ២. | លោក | **អ៊ុច តា** | អភិបាលរងខេត្ត | អនុប្រធាន |
| ៣. | លោក | **ញឹម ស្រ៊ន** | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិកអចិន្ត្រៃយ៍ |

| | | | | |
|---|---|---|---|---|
| ៤. | លោក | **កែត ព្រុង** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | សមាជិក |
| ៥. | លោក | **ទស់ ស៊ីណា** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ៦. | លោក | **ប្រាក់ ប៊ិន** | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | សមាជិក |
| ៧. | លោក | **ភង ឥន្ទ្រី** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៨. | លោក | **មូល វិចិត្រ** | អភិបាលក្រុងដូនកែវ | សមាជិក |
| ៩. | លោក | **ខឹម គឹមសាន** | អភិបាលស្រុកអង្គបុរី | សមាជិក |
| ១០. | លោក | **នាង ស៊ិន** | អភិបាលស្រុកកោះអណ្តែត | សមាជិក |
| ១១. | លោក | **អ៊ុត សារ** | អភិបាលស្រុកព្រៃកប្បាស | សមាជិក |
| ១២. | លោក | **ស៊ុត ខុន** | អភិបាលស្រុកបូរីជលសារ | សមាជិក |
| ១៣. | លោក | **ញ៉ែម ស្រស់** | អភិបាលស្រុកសំរោង | សមាជិក |
| ១៤. | លោក | **កែត ម៉ៅ** | អភិបាលស្រុកទ្រាំង | សមាជិក |
| ១៥. | លោក | **តឹក តុងលីម** | អភិបាលស្រុកត្រាំកក់ | សមាជិក |
| ១៦. | លោក | **អ៊ុក រី** | អភិបាលស្រុកបាទី | សមាជិក |
| ១៧. | លោក | **កៅ វត្តសែល** | អភិបាលស្រុកគិរីវង់ | សមាជិក |
| ១៨. | លោកស្រី | **គា សុតូ** | នាយករងរដ្ឋបាលសាលាខេត្ត | លេខាធិការ |
| ១៩. | កញ្ញា | **ម៉ន រតនា** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្តស្តីទី | ជំនួយការ |

**ប្រការ ២._**

គណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលយ៉ាងជិតស្និតជាមួយនិងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញ ចលនាភូមិ១ ផលិតផល១។
- ជំរុញការអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យ ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណជំហានទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។
- អភិវឌ្ឍន៍ធនធានមនុស្សទាក់ទងទៅនឹងការជំរុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យរួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ពលរដ្ឋ តាមសហគមន៍។
- ចូលរួម និងដឹកនាំការសិក្សាស្រាវជ្រាវផលិតផល ជាសក្តានុពលនានាដែលមានក្នុងខេត្ត ទាំងផលិតផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្ម ដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍផលិតផលទាំងនោះមានលក្ខណៈ កាន់តែប្រសើរ កាន់តែពិសេស និងសមស្របតាមទីផ្សារទាំងក្នុងសហគមន៍ក្នុងប្រទេស និងក្រៅប្រទេស។

- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈសំខាន់នៃការជំរុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្ត ប្រជាជននៅតាមមូលដ្ឋានឲ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ។
- សម្របសម្រួលជាមួយអង្គការ ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអនុវត្តន៍ ចលនាភូមិ១ ផលិតផល១។
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីផែនការសកម្មភាពជំរុញ ចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត។
- រៀបចំបង្កើតសមាគម ឬសហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត។
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅក្នុងខេត្ត សម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយ ប្រមូលផ្តុំ និងដាក់តាំងបង្ហាញ ឬលក់ផលិតផលភូមិ១ ផលិតផល១។
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង ស្រុក ជំរុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាព និង តួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការ ខេត្តជំរុញចលនាភូមិ១ ផលិតផល១។
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ជំរុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរ ស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បី រួមសហការប្រតិបត្តិក្នុងការជំរុញចលនាភូមិ១ ផលិតផល១។

**ប្រការ ៣.**

ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការខេត្ត ជំរុញចលនាភូមិ១ ផលិតផល១ (គ.ខ.ភ១.ផ១) មានដូចខាង ក្រោម៖

- គ.ខ.ភ១.ផ១ មានសិទ្ធរៀបចំបែងចែក ភារកិច្ចទទួលខុសត្រូវលំអិតបន្ថែមទៀតសម្រាប់ជំរុញចលនា ភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត និងក្រុងស្រុករបស់ខ្លួន។
- គ.ខ.ភ១.ផ១ មានលេខាធិការដ្ឋានមួយ ដឹកនាំដោយនាយក ឬនាយករងរដ្ឋបាល០១រូប និងមានជំនួយ ការមួយចំនួនជាមន្ត្រីរដ្ឋបាលសាលាខេត្ត ទៅតាមការចាំបាច់ ដោយមានការឯកភាពពីប្រធានគណៈ កម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។
- គ.ខ.ភ១.ផ១ អាចអញ្ជើញតំណាងមន្ទីរ អង្គភាពផ្សេងទៀតក្នុងខេត្ត តំណាងអង្គការមិនមែន រដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាងវិស័យឯកជន និងតំណាងសហគមន៍ ឬសមាគមចូលរួម ប្រជុំផ្តល់យោបល់ ពិភាក្សាគ្នាក្នុងការអនុវត្តភារកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១ នៅ ក្នុងខេត្តរបស់ខ្លួន។
- សមាជិក គ.ខ.ភ១.ផ១ ត្រូវចូលរួមប្រជុំរៀងរាល់ ៣ខែម្តង និងករណីពិសេសណាមួយតាមការ អញ្ជើញរបស់ប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១។

- កិច្ចប្រជុំរៀងរាល់ ៣ខែម្តង ឬករណីពិសេសណាមួយ ត្រូវស្ថិតនៅក្រោមអធិបតីភាពប្រធានគណៈកម្មាធិការខេត្តជំរុញចលនាភូមិ១ ផលិតផល១ ឬអនុប្រធានគណៈកម្មាធិការ ដែលត្រូវបានទទួលការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការ។

**ប្រការ ៤.**

រាល់សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសាផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.**

លោកនាយករដ្ឋបាលសាលាខេត្ត លោក លោកស្រីប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ លោកអភិបាលក្រុង ស្រុកគ្រប់ស្រុក សាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ឲ្យទទួលបានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អភិបាលខេត្ត**

**ឡាយ វណ្ណៈ**

**កន្លែងទទួល ៖**

- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញភូមិ១ ផលិតផល១
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ